ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៛ ❖ ៚

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៦១៧ អយក-ប្រក

ប្រកាស
ស្តីពីការបើកសាលាបឋមសិក្សា ក្បាលកោះ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាខេត្ត កំពង់ឆ្នាំង លេខ ១៦២៩ អយក.កន ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០២ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ១** :- បើកសាលាបឋមសិក្សា **ក្បាលកោះ** ជាផ្លូវការដែលមានទីតាំងស្ថិតនៅភូមិ **ក្បាលកោះ** ឃុំ **អំពិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **កំពង់ក្តារ** ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **ក្បាលកោះ** ត្រូវមានប្រធានក្រុមម្នាក់ទទួលខុសត្រូវរួមជាមួយនាយក សាលាបឋមសិក្សា **កំពង់ក្តារ** ។

**ប្រការ៣** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ឆ្នាំង** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កំពង់ត្រឡាច** នាយកសាលាបឋមសិក្សា **កំពង់ក្តារ** និងប្រធានក្រុមសាលាឧបសម្ព័ន្ធ **ក្បាលកោះ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

ឌុំ ស_ឌិទ្ធី

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាបជាពត៌មាន "
- សាលាខេត្ត កំពង់ឆ្នាំង

" ជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ
- ឯកសារ នា -ប.ម